# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សាលក្រមលេខ: ៣៦ "ឃ"
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២
សំណុំរឿងរដ្ឋប្បវេណីលេខ: ៩១
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។

លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៩១ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។

ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជី

**-ដើមចោទ**

ធនាគារ [redacted] សាខាខេត្តកំពង់ស្ពឺ មានអាសយដ្ឋាននៅផ្លូវ [redacted] តំណាងដោយលោក [redacted] ចិត្រ្តា ភេទប្រុស អាយុ៣២ ឆ្នាំ ជនជាតិខ្មែរ តួនាទី នាយកសាខា [redacted] សាខាខេត្តកំពង់ស្ពឺ។

**-សហចុងចម្លើយ**

១-ឈ្មោះ [redacted] សម្ផស្ស ([redacted] សម្ផស្ស) ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨៤ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ ២០១៦ មុខរបរ: យោធា មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted]។

២-ឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ កើតថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៨៨ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ មុខរបរ: នៅផ្ទះ មានអាសយដ្ឋាន [redacted]

-លោកមេធាវី [redacted] អត្តលេខ ១៩៨៨ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃ [redacted]



Scanned with CamScanner

[redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ឈ្មោះ [redacted] សម្ផស្ស ([redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា)។

-លោកមេធាវី [redacted] អត្តលេខ ២២១០ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៅការិយាល័យ [redacted] មានការិយាល័យនៅ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស)។

៣-ឈ្មោះ [redacted] សាមិត ភេទប្រុស អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ កើតថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៧២ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] មុខរបរៈ កាប់ជ្រូក មានអាសយដ្ឋានបច្ចុប្បន្ន [redacted]

៤-ឈ្មោះ [redacted] សាព៉ាន់ [redacted] សាព៉ាន់) ភេទស្រី អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ កើតថ្ងៃទី០៥ ខែមករា ឆ្នាំ ១៩៧៧ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] មុខរបរៈ លក់ដូរ មានអាសយដ្ឋាន [redacted]

-មេធាវី [redacted] អត្តលេខ ១៩៥៦, [redacted] អត្តលេខ ១៩៦១, [redacted] អត្តលេខ ១៩៦៧, [redacted] អត្តលេខ ១២៣៣, [redacted] អត្តលេខ ២៤៣០T , [redacted] អត្តលេខ ២៤៣៩T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សាព៉ាន់ ([redacted] សាព៉ាន់)។

## អង្គហេតុ និងចំណុចវិវាទ

<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖</u>

១-បង្គាប់ឱ្យសហចុងចម្លើយ សងប្រាក់ដើមចំនួន ៤២.៥០០,០៣ (បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ។

២-បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ២២.០៤៨,៧៦ (ពីរម៉ឺនពីរពាន់សូន្យរយសែសិបប្រាំបីក្បៀសចិតសិបប្រាំមួយ) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

៣-បង្គាប់ឱ្យសហចុងចម្លើយ សងប្រាក់ពិន័យចំនួន ៥០.៦៥២,៩៥ (ប្រាំម៉ឺនសូន្យពាន់ប្រាំមួយរយហាសិបពីរក្បៀសកៅសិបប្រាំ) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

៤-បង្គាប់ឱ្យសហចុងចម្លើយបង់អត្រាការប្រាក់ចំនួន ១,២% ក្នុងមួយខែ និងប្រាក់ពិន័យចំនួន ២៤% ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ខកខានមិនបានសង ដែលសមាមាត្រទៅនឹងថ្ងៃខកខានសងមកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៥-បង្គាប់ឱ្យសហចុងចម្លើយសងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសោហ៊ុយផ្នែកច្បាប់ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

៦-សុំប្រកាសអនុវត្តសាលក្រមនេះជាបណ្ដោះអាសន្ន។

៧-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

## ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ឈ្មោះ [redacted] សម្ផស្ស និងប្រពន្ធឈ្មោះ [redacted] លក្ខិណា បានខ្ចីឥណទានពី ធនាគារ [redacted] សាខាខេត្តកំពង់ស្ពឺ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក រយៈពេល ៦០ខែ ដែលមានអត្រាការប្រាក់ចំនួន ១,២% ក្នុងមួយខែ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងមានអ្នកធានា ព្រមទាំងបញ្ចាំជំនួសឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់។ បន្ទាប់ពីទទួលបានប្រាក់កម្ចីពីធនាគារ សហចុងចម្លើយបានបង់រំលស់សងប្រាក់ទៅតាមកាលវិភាគសងប្រាក់ជាធម្មតា ប៉ុន្តែចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន សហចុងចម្លើយពុំបានអនុវត្តតាមតារាងកាលវិភាគសងប្រាក់ និងតាមកិច្ចសន្យាខ្ចីប្រាក់នោះទេ។ ធនាគារបានសម្របសម្រួលដោយទុកពេលវេលាឱ្យ ជូនដំណឹងទៅសហចុងចម្លើយ ដើម្បីអនុវត្តកាតព្វកិច្ច ប៉ុន្តែ សហចុងចម្លើយនៅតែមិនបានអនុវត្តកាតព្វកិច្ចរហូតមកដល់បច្ចុប្បន្នដដែល។ ទង្វើរបស់ សហចុងចម្លើយបានបង្កនូវព្យសនកម្ម និងធ្វើឱ្យរាំងស្ទះដល់ដំណើរការចរន្តសាច់ប្រាក់ ក្នុងប្រព័ន្ធធនាគាររបស់ធនាគារយ៉ាងខ្លាំង។

## ការអះអាងរបស់ភាគី

-ឈ្មោះ [redacted] ចិត្រ្តា តំណាងឱ្យដើមចោទធនាគារ [redacted] ធ្វើសេចក្តីថ្លែងការណ៍ស្តីពីលទ្ធផលត្រៀមសម្រាប់ការទាញហេតុផលថាៈ សុំរក្សាកំណត់ហេតុស្តីពីនីតិវិធីត្រៀមលើកទីបី ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែល។ ដោយកាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ សហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស ([redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) បានមកខ្ចីប្រាក់ពីធនាគារ [redacted] សាខាខេត្តកំពង់ស្ពឺ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ក្នុងរយៈពេល ៦០ខែ ដែលមានអត្រាការប្រាក់ចំនួន ១,២% ក្នុងមួយខែ តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងមានអ្នកធានាឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ [redacted] សាវ៉ាន់) ក្នុងការខ្ចីប្រាក់នេះ ដោយអ្នកទាំងពីរឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ [redacted] សាវ៉ាន់) បានយកដីមួយប្លង់មានទំហំ ៣៥.០០០ (បីម៉ឺនប្រាំពាន់) ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា (ត្រពាំងថ្លុង) ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដើម្បីមកធានាបំណុលខាងលើ។ បន្ទាប់ពីទទួលបានប្រាក់កម្ចីពីធនាគារ សហចុងចម្លើយបានបង់រំលស់សងប្រាក់ទៅតាមកាលវិភាគសងប្រាក់មកធនាគារជាធម្មតា រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ ទើបសហចុងចម្លើយខកខានបង់ប្រាក់មកធនាគារ រហូតមកដល់បច្ចុប្បន្ន ដោយខាងធនាគារបានជូនដំណឹងទៅសហចុងចម្លើយត្រឹមត្រូវតាមទូរស័ព្ទ និងទៅជួបផ្ទាល់ ដើម្បីឱ្យសហចុងចម្លើយមកបង់ប្រាក់ និងផ្តល់ដំណោះស្រាយឱ្យសហចុងចម្លើយ ហើយសហចុងចម្លើយបានសំណូមពរមកធនាគារ ដោយក្នុងមួយខែសុំបង់ប្រាក់ចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ក្នុងមួយខែ ប៉ុន្តែសហចុងចម្លើយមិនបានអនុវត្តទៅតាមការសន្យានោះទេ រហូតដល់មានការសម្របសម្រួលគ្នា ប្រសិនបើសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) មានប្រាក់ដើមចំនួន ៤២.៥០០,០៣ (បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក មកបង់ជូនធនាគារ ភាគីធនាគារនឹងដាក់គោលការណ៍ ស្នើសុំទទួលយកប្រាក់ដើមខាងលើទៅថ្នាក់គ្រប់គ្រងដើម្បីសម្រេច តែសហចុងចម្លើយនៅតែមិនបានបង់ប្រាក់ដើមមកឱ្យខាងធនាគារទៀត ទើបធនាគារប្រៃសណីយ៍ សាខាខេត្តកំពង់ស្ពឺ សម្រេចចិត្តដាក់ពាក្យបណ្តឹងដូចក្នុងកម្មវត្ថុខាងលើ។ ដោយខ្ញុំបាទសុំបញ្ជាក់បន្ថែមថា

ចំពោះសហចុងចម្លើយឈ្មោះ [redacted] សម្ពស្ស [redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) បានផ្ទេរកម្មសិទ្ធិករថ្មី ដែលផ្ទុយពីកម្មសិទ្ធិករ ដែលបានដាក់បញ្ចាំនៅធនាគារ ហើយកម្មសិទ្ធិករថ្មីនោះ គឺជាឪពុកម្តាយ និងបងប្អូនរបស់សហចុងចម្លើយឈ្មោះ [redacted] សម្ពស្ស [redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ហើយចំពោះសហចុងម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សាភ័ន់ [redacted] សាភ័ន់) បានស្នើសុំចុះវាស់វែងជាប្រព័ន្ធទៅលើដីដែលបានដាក់បញ្ចាំនៅធានាគារ ដែលមានទំហំ ៣៥.០០០ (បីម៉ឺនប្រាំពាន់) ម៉ែត្រការ៉េ ស្ថិតនៅភូមិទឹកថ្លា (ត្រពាំងថ្លុង) ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិលក្ខណៈជាប្រព័ន្ធ នៅក្នុងដំណើរការចុះវាស់វែងនេះ ខាងធនាគារបានដឹងហើយក៏បានជូនដំណឹងទៅអាជ្ញាធរមានភូមិឃុំ និងមន្ត្រីសុរយោដី ព្រមទាំងឪពុកម្តាយរបស់សហចុងចម្លើយ តែនៅតែចេញប្លង់បានចំពោះឪពុកម្តាយ និងបងប្អូនរបស់សហចុងចម្លើយ។ ខ្ញុំបាទថ្លែងការណ៍ពីពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១.បង្គាប់សហចុងចម្លើយសងប្រាក់ដើមចំនួន ៤២.៥០០,០៣ (បួនម៉ឺនពីរពាន់ប្រាំរយកៀសសូន្យបីសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ។

២.បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ២២.០៤៨,៧៦ (ពីរម៉ឺនពីរពាន់សូន្យរយសែសិបប្រាំបីកៀសចិតសិបប្រាំមួយសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

៣.បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ពិន័យចំនួន ៥០.៦៥២,៩៥ (ប្រាំម៉ឺនសូន្យពាន់ប្រាំមួយរយហាសិបពីរកៀសកៅសិបប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ ចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

៤.បង្គាប់ឱ្យសហចុងចម្លើយបង់អត្រាការប្រាក់ចំនួន ១,២% ក្នុងមួយខែ និងប្រាក់ពិន័យចំនួន ២៤% ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ខកខានមិនបានសង ដែលសមាមាត្រទៅនឹងថ្ងៃខកខានសងមកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៥.បង្គាប់ឱ្យសហចុងចម្លើយសងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

៦.សុំប្រកាសអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ន លើចំណុចទាំងអស់នៃការទាមទារ។

៧.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

-លោក [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ពស្ស [redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ធ្វើសេចក្តីថ្លែងការណ៍តបថា: នៅក្នុងរឿងនេះ កូនក្តីខ្ញុំបាទទទួលស្គាល់ការទាមទារ ដោយបញ្ជាក់ថា កន្លងមកកូនក្តីខ្ញុំបាទពិតជាបានខ្ចីប្រាក់ពីធនាគារប្រៃសណីយ៍ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ១,២% ក្នុងមួយខែប្រាកដមែន ដោយបានបង់ប្រាក់ទៅធនាគារបានមួយចំនួន និងស្នើសុំទៅធនាគារ ដាក់តួលេខទឹកប្រាក់ (តារាងតុល្យការបង់កម្ចី) ឱ្យបានច្បាស់លាស់ ហើយប្រពន្ធរបស់កូនក្តីខ្ញុំបាទក៏បានចូលរួមក្នុងការខ្ចីប្រាក់នេះដែរ ហើយកូនក្តីខ្ញុំបាទស្នើសុំទៅធនាគារឱ្យដកឈ្មោះអ្នកធានាឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សាភ័ន់ [redacted] សាភ័ន់) ចេញ ដោយកូនក្តីខ្ញុំបាទ និងប្រពន្ធជាអ្នកទទួលខុសត្រូវទាំងអស់ ព្រោះប្រាក់ទាំងអស់នេះ គឺកូនក្តីខ្ញុំបាទជាអ្នកខ្ចីទេ។ នៅក្នុងរឿងនេះ កូនក្តីខ្ញុំបាទពិតជាបានខ្ចីប្រាក់ពីដើមចោទចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ប្រាកដមែន ដោយកូនក្តីខ្ញុំបាទបានសងប្រាក់ទៅដើមចោទបានខ្លះ ដោយនៅ

ប្រាក់ដើមចំនួន ៤២.៥០០,០៣ (បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក ដោយសារបច្ចុប្បន្នកូនក្តីខ្ញុំបាទជួបបញ្ហាសេដ្ឋកិច្ចនៅក្នុងគ្រួសារ ពុំមានលទ្ធភាពសងការ និងប្រាក់ពិន័យជូនទៅភាគីដើមចោទនោះទេ និងស្នើសុំឱ្យដើមចោទអនុញ្ញាតឱ្យកូនក្តីខ្ញុំបាទបង់ប្រាក់រំលស់ជាខែ ដោយក្នុងមួយខែចំនួន ៥០០ (ប្រាំរយ) ដុល្លារអាមេរិក និងស្នើសុំដល់តុលាការមេត្តាប្រានចោលត្រង់ចំណុច ទី២, ទី៣, ទី៤ និងទី៥ នៃកម្មវត្ថុបណ្តឹង ដោយសុំឱ្យតុលាការបង្គាប់ឱ្យកូនក្តីខ្ញុំបាទសងតែប្រាក់ដើមតែប៉ុណ្ណោះ។ ចំពោះឯកសារភស្តុតាងកូនក្តីខ្ញុំបាទមិនមានឯកសារដាក់ជូនតុលាការពិនិត្យនោះទេ។ ហើយមួយទៀតដើមចោទស្នើសុំសាលក្រមអនុវត្តបណ្តោះអាសន្នគ្រប់ចំណុចនោះ ខ្ញុំបាទស្នើសុំឱ្យតុលាការប្រានចោលការទាមទារត្រង់ចំណុចនេះ។

-សហចុងចម្លើយឈ្មោះ [redacted] សាមិត ធ្វើសេចក្តីថ្លែងការណ៍តបថា: នៅក្នុងរឿងនេះ ខ្ញុំបាទស្នើសុំឱ្យមេធាវីរបស់ខ្ញុំបាទធ្វើសេចក្តីថ្លែងការណ៍ទាំងស្រុង។

-សហចុងចម្លើយឈ្មោះ [redacted] សាភ៉ាន់ [redacted] សាភ៉ាន់) ធ្វើសេចក្តីថ្លែងការណ៍តបថា: នៅក្នុងរឿងនេះនាងខ្ញុំស្នើសុំឱ្យមេធាវីរបស់នាងខ្ញុំធ្វើសេចក្តីថ្លែងការណ៍ទាំងស្រុង។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សាភ៉ាន់ [redacted] សាភ៉ាន់) ធ្វើសេចក្តីថ្លែងការណ៍តបថា: នៅក្នុងរឿងនេះ ខ្ញុំបាទស្នើសុំប្រានចោលការទាមទាររបស់ដើមចោទទាំងស្រុង ដោយហេតុថា ការខ្ចីនេះ គឺមានសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ជាអ្នកខ្ចីពីធនាគារនោះទេ គឺមិនមានការពាក់ព័ន្ធជាមួយនឹងកូនក្តីខ្ញុំបាទឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សាភ៉ាន់ [redacted] សាភ៉ាន់) នោះទេ ដោយឡែកនៅក្នុងពាក្យបណ្តឹងរបស់ដើមចោទ បានទាមទារប្រាក់ឱ្យកូនក្តីខ្ញុំបាទចូលរួមសងក្នុងនាមជាសហចុងចម្លើយទៅវិញ។ ដោយកូនក្តីខ្ញុំបាទបានលើកឡើងមកហើយ គឺឱ្យកូនក្តីខ្ញុំបាទដាក់តម្កល់ប្លង់ក្នុងរយៈពេល ០៦ខែ អាចដកវិញបាន តែផ្ទុយទៅវិញខាងធនាគារបានធ្វើកិច្ចសន្យាដាក់បញ្ចាំ ដាក់ធានា ឱ្យកូនក្តីខ្ញុំបាទផ្តិតមេដៃទៅវិញ ដោយខាងធនាគារ គឺមិនបានប្រាប់អំពីខ្លឹមសារនៃលិខិតនីមួយៗឱ្យកូនក្តីខ្ញុំបាទបានដឹងនោះទេ ដូច្នេះ ផ្ទុយពីបញ្ញត្តិមាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណី ការបង្ហាញឆន្ទៈដែលមានវិការៈហើយទាក់ទងទៅនឹងកិច្ចសន្យាធានា គឺធ្វើឡើងមិនត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ដោយយោងមាត្រា ៩០១ ក្រមរដ្ឋប្បវេណី ទម្រង់ចាំបាច់នៃកិច្ចធានា ត្រង់កថាខណ្ឌទី២ ហើយទាក់ទងទៅនឹងកិច្ចសន្យាបញ្ចាំ គឺមិនត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ការបញ្ចាំក្នុងមាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី ការប្រាក់នៃសិទ្ធិលើបំណុល គឺខាងធនាគារមិនអាចទាមទារការប្រាក់បាននោះទេ ហើយមួយទៀតខាងសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) គាត់ក៏បានធានាក្នុងការសងប្រាក់ទៅធនាគារដែរ ដូច្នេះស្នើសុំឱ្យតុលាការសម្រេចដកកូនក្តីខ្ញុំបាទឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សាភ៉ាន់ (ម៉ន សាភ៉ាន់) ចេញពីការធានា និងសុំឱ្យតុលាការសម្រេចបង្គាប់ទៅធនាគារឱ្យប្រគល់ប្លង់ដីរបស់កូនក្តីខ្ញុំបាទមកឱ្យកូនក្តីខ្ញុំបាទវិញ។ មួយទៀតស្នើសុំឱ្យតុលាការបង្គាប់ឱ្យដើមចោទហៅមន្ត្រីឥណទានពាក់ព័ន្ធក្នុងការខ្ចីប្រាក់នេះមកតុលាការ ដើម្បីឆ្លើយបញ្ជាក់ឱ្យបានច្បាស់។ ដើមចោទលើកឡើងថា កូនក្តីខ្ញុំបាទធ្លាប់នូវការខ្ចីប្រាក់ពីធនាគារផ្សេង ដែលនាំឱ្យកូនក្តីខ្ញុំបាទយល់នូវអ្វីជាកិច្ចសន្យាខ្ចីប្រាក់ អ្វីជាកិច្ចសន្យាបញ្ចាំ អ្វីជាកិច្ចសន្យាធានា ហេតុនេះស្នើសុំឱ្យដើមចោទបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា កូនក្តីខ្ញុំបាទធ្លាប់ខ្ចីលុយពីធនាគារដែលនាំឱ្យកូនក្តីបាទយល់ពីអ្វីទៅដែលជាកិច្ចសន្យានោះ។ ហើយខាងដើមចោទលើកឡើងថា មន្ត្រីឥណទានបានឈប់ពីការងារ ហេតុនេះ ខ្ញុំបាទស្នើសុំដើមចោទផ្តល់ឯកសារពីលិខិតលាលែងពីការងាររបស់

មន្ត្រីឥណទាននោះថា ពិតជាបានឈប់ពីការងារមែន ឬយ៉ាងណា និងស្នើសុំឱ្យតុលាការពិនិត្យអង្គច្បាប់នៃមាត្រាដែលសហភាតារបស់ខ្ញុំបាទបានលើកឡើងខាងលើ ព្រោះថា ខាងធនាគារមិនប្រាកដថា ធ្វើឯកសារត្រឹមត្រូវតាមផ្លូវច្បាប់ទាំងអស់នោះដែរ។ អំពីអង្គហេតុ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ឈ្មោះ [redacted] សម្ផស្ស ([redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) បានស្នើសុំខ្ចីប្រាក់ពីធនាគារប្រៃសណីយ៍កម្ពុជា សាខាខេត្តកំពង់ស្ពឺ ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយខ្ចីនោះក្នុងរយៈពេល ៦០ (ហុកសិប) ខែ ដែលមានអត្រាការប្រាក់ចំនួន ១,២% ក្នុងមួយខែ ដូចមាននៅក្នុងកិច្ចសន្យាប្រាក់ ចុះនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។ នៅក្នុងការខ្ចីនេះ ខាងធនាគារតម្រូវឱ្យមានអ្នកធានា ដោយមានការរាប់អានគ្នាកូនក្តីពួកខ្ញុំឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ([redacted] សាវ៉ាន់) ក៏បានយល់ព្រមផ្តិតមេដៃធានាឱ្យទៅឈ្មោះ [redacted] សម្ផស្ស [redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ដោយមិនបានផលប្រយោជន៍អ្វីពីការខ្ចីប្រាក់នេះទេ។ ចំពោះប្រតិបត្តិការណ៍ខ្ចីប្រាក់នេះ ឈ្មោះ [redacted] សម្ផស្ស [redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ក៏បានយកដីដែលជាទ្រព្យសម្បត្តិរបស់ខ្លួនមួយចំនួនមកដាក់បញ្ចាំជាមួយធនាគារផងដែរ ប៉ុន្តែដោយទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] សម្ផស្ស [redacted] សម្ភស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ដែលដាក់បញ្ចាំនេះមានតម្លៃមិនគ្រប់ចំនួននៃប្រាក់កម្ចីពីធនាគារ ទើបមន្ត្រី [redacted] សាខាខេត្តកំពង់ស្ពឺ បានប្រាប់មកកូនក្តីពួកខ្ញុំថា ត្រូវយកទ្រព្យសម្បត្តិរបស់អ្នកធានាមកតម្កល់ជាមួយធនាគារមួយទៀត ទើបគ្រប់ចំនួននៃប្រាក់កម្ចីនេះ ដោយនៅពេលនោះខាងមន្ត្រីធនាគារប្រៃសណីយ៍កម្ពុជា សាខាខេត្តកំពង់ស្ពឺ បានប្រាប់ថា ការតម្កល់ទ្រព្យសម្បត្តិរបស់អ្នកធានានេះ គឺដាក់តម្កល់តែរយៈពេល ០៦ (ប្រាំមួយ) ខែ តែប៉ុណ្ណោះ អាចដកយកមកវិញហើយ។ ដោយកូនក្តីពួកខ្ញុំយល់ឃើញថា ការដាក់តម្កល់ទ្រព្យសម្បត្តិរបស់ខ្លួន តែរយៈពេល ០៦ (ប្រាំមួយ) ខែ បែបនេះ ទើបកូនក្តីពួកខ្ញុំបានសម្រេចចិត្តយកឯកសារដីចំការមួយកន្លែងទំហំ ៣៥.០០០ (បីម៉ឺនប្រាំពាន់) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិទឹកថ្លា ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មកដាក់តម្កល់ជាមួយធនាគារ ដោយនៅពេលនោះមន្ត្រីធនាគារក៏រៀបចំឯកសារមួយចំនួនឱ្យកូនក្តីពួកខ្ញុំផ្តិតមេដៃ ដោយប្រាប់ថា ផ្តិតមេដៃលើឯកសារធានា និងឯកសារតម្កល់ប្លង់ដី។ លុះដល់រយៈពេលនៃការដកយកប្លង់ដីដែលបានដាក់តម្កល់ជាមួយធនាគារនោះវិញ ទើបកូនក្តីពួកខ្ញុំបានស្នើសុំដកយកប្លង់ពីធនាគារវិញ ប៉ុន្តែខាងធនាគារមិនឯកភាពប្រគល់ឱ្យកូនក្តីពួកខ្ញុំវិញនោះទេ ដោយខាងធនាគារប្រាប់ថា ឯកសារដីនេះមិនមែនដាក់តម្កល់រយៈពេល ០៦ខែ នោះទេ គឺដាក់បញ្ចាំជាមួយនឹងធនាគារដូចមានកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។ ដោយដឹងបែបនេះ ទើបកូនក្តីពួកខ្ញុំដឹងថា មន្ត្រីធនាគារមានចេតនាលួងលោមកូនក្តីពួកខ្ញុំឱ្យដាក់ទ្រព្យសម្បត្តិមកបញ្ចាំជាមួយធនាគារ ដែលធ្វើឱ្យកូនក្តីពួកខ្ញុំបង្ហាញឆន្ទៈ ដែលមានវិការៈក្នុងការសម្រេចចិត្តយកទ្រព្យសម្បត្តិរបស់ខ្លួនមកដាក់ធានាលើបំណុលនេះ ដែលផ្ទុយពីបញ្ញត្តិមាត្រា ៣៨៥ នៃក្រមរដ្ឋប្បវេណី។ លុះក្រោយមកទៀត នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ស្រាប់តែខាងធនាគារប្រៃសណីយ៍កម្ពុជា សាខាខេត្តកំពង់ស្ពឺ បានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារលើដីរបស់កូនក្តីពួកខ្ញុំមកសាលាដំបូងខេត្តកំពង់ស្ពឺ ហើយនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ សាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចចេញដីកាសម្រេចរក្សាការពារលេខ: ៨១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ តាមពាក្យសុំរបស់ធនាគារ [redacted] សាខាខេត្តកំពង់ស្ពឺ ដែលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់កូនក្តីពួកខ្ញុំយ៉ាងខ្លាំង បន្ទាប់មកទៀតនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ខាងធនាគារប្រៃសណីយ៍កម្ពុជា សាខាខេត្តកំពង់ស្ពឺ បានដាក់ពាក្យបណ្តឹងទាមទារប្រាក់ ដោយនៅក្នុងពាក្យបណ្តឹង

នោះបានដាក់កូនក្តីពួកខ្ញុំឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ជាសហចុងចម្លើយ ដោយទាមទារឱ្យកូនក្តីពួកខ្ញុំសងប្រាក់ដើម ប្រាក់ពិន័យ និងការប្រាក់ទៅឱ្យខាងធនាគារ ជាមួយនឹងចុងចម្លើយឈ្មោះ [redacted] សម្ផស្ស និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ទៅវិញ។ ការដែលខាងដើមចោទ យកកូនក្តីពួកខ្ញុំដែលជាអ្នកធានាមកធ្វើជាសហចុងចម្លើយបែបនេះ មិនត្រឹមត្រូវនោះទេ ដោយហេតុថាកូនក្តីពួកខ្ញុំគាត់មានឋានៈជាអ្នកធានានៅក្នុងការខ្ចីប្រាក់នេះ ដូច្នេះកាតព្វកិច្ចរបស់គាត់បន្ទាប់បន្សំពីកាតព្វកិច្ចចម្បងរបស់កូនបំណុលឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) តែប៉ុណ្ណោះ។ ចំពោះរឿងនេះចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ក៏បានបង្ហាញឆន្ទៈរបស់គាត់ក្នុងការទទួលខុសត្រូវសងប្រាក់ទាំងអស់ជូនធនាគារ ដោយមិនឱ្យពាក់ព័ន្ធជាមួយនឹងកូនក្តីពួកខ្ញុំឡើយ។ ម្យ៉ាងទៀតការខ្ចីប្រាក់នេះ ចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ក៏បានសងប្រាក់ទៅធនាគារបានមួយចំនួនរួចហើយដែរ និងទ្រព្យសម្បត្តិដាក់បញ្ចាំដើម្បីធានាសម្រាប់យកមកទូទាត់ សងប្រាក់ជូនធនាគារផងដែរ។ អង្គច្បាប់ មាត្រា ៣៩៥ នៃក្រមរដ្ឋប្បវេណី "ការបង្ហាញឆន្ទៈដែលមានវិការៈ "អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈតាមបញ្ញត្តិនៃផ្នែកទី២ (វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា) នេះ និងផ្នែកទី៣ (មោឃភាព និងការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ៖

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយ អំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។

-មាត្រា ៩០១ នៃក្រមរដ្ឋប្បវេណី "ទម្រង់ចាំបាច់នៃកិច្ចសន្យាធានា"

១-ការធានាដោយគ្មានលិខិតជាលាយលក្ខណ៍អក្សរអាចដកវិញនៅពេលណាក៏បាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកធានាបានចាប់ផ្តើមអនុវត្តកាតព្វកិច្ចធានានោះដោយស្ម័គ្រចិត្ត។

២-បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះករណីដែលចំនួនទឹកប្រាក់នៃកាតព្វកិច្ចធានា មិនត្រូវបានសរសេរជាអក្សរដោយផ្ទាល់ដៃរបស់អ្នកធានា ក្នុងការធានាកាតព្វកិច្ចដែលមានបំណងសងជាប្រាក់។

៣-លិខិតជាលាយលក្ខណ៍អក្សរនៃការធានា ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីខ្លឹមសារនៃកាតព្វកិច្ចធានា។ មាត្រា ៨៣៦ នៃក្រមរដ្ឋប្បវេណី "ការប្រាក់នៃសិទ្ធិលើបំណុល" ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ។

-មាត្រា ៩០៤ នៃក្រមរដ្ឋប្បវេណី "លក្ខណៈនៃការធានា"

១-កិច្ចសន្យាធានាមិនអាចកើតឡើងបានឡើយ នៅក្នុងករណីដែលគ្មានកាតព្វកិច្ចចម្បង។ ប៉ុន្តែកិច្ចសន្យាធានាអាចកើតឡើងបាន ចំពោះកាតព្វកិច្ចដែលនឹងកើតមានឡើងនៅពេលអនាគត ឬកាតព្វកិច្ចដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ។

២-ក្នុងករណីដែលបន្ទុករបស់អ្នកធានាធ្ងន់ជាងកាតព្វកិច្ចចម្បង ដោយគិតទាំងកម្មវត្ថុ ឬល័ក្ខខ័ណ្ឌនោះ ត្រូវបន្ថយបន្ទុករបស់អ្នកធានាធ្ងន់ត្រឹមកម្រិតនៃកាតព្វកិច្ចចម្បង។

៣-ក្នុងករណីដែលកាតព្វកិច្ចចម្បងរលត់ កាតព្វកិច្ចធានាក៏ត្រូវរលត់ផងដែរ។

៤-ការផ្អាកអាជ្ញាយុកាលដោយការទាមទារចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬដោយមូលហេតុផ្សេងៗទៀត ក៏មានអានុភាពចំពោះអ្នកធានាផងដែរ។

៥-ក្នុងករណីដែលសិទ្ធិលើបំណុលចំពោះកូនបំណុល ដែលមានកាតព្វកិច្ចចម្បងត្រូវបានធ្វើអនុប្បទាន នោះសិទ្ធិលើបំណុល ចំពោះអ្នកធានាក៏ត្រូវចាត់ទុកថា បានធ្វើអនុប្បទានផងដែរ លើកលែងតែមានការសន្យាពិសេស។ ដោយសំណូមពរ សុំប្រានចោលការទាមទាររបស់ដើមចោទដូចមាននៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ទាំងស្រុង, ទីពីរស្នើសុំតុលាការដកកូនក្ដីខ្ញុំបាទឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ចេញពីអ្នកធានា និងទីបីស្នើសុំឱ្យតុលាការបង្គាប់ឱ្យដើមចោទប្រគល់ប្លង់ដីដែលដាក់ធានាមកឱ្យកូនក្ដីខ្ញុំបាទវិញ។ ចំពោះឯកសារភស្តុតាងខាងកូនក្ដីខ្ញុំបាទមិនមានដាក់ជូនតុលាការពិនិត្យនោះទេ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ធ្វើសេចក្ដីថ្លែងការណ៍តបថា: ខ្ញុំបាទសុំរក្សាតាមសេចក្ដីថ្លែងការណ៍ និងការទាមទាររបស់មេធាវីសហភាតាលោក [redacted] ទុកជាបានការដដែលទាំងស្រុង។

-លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ធ្វើសេចក្ដីថ្លែងការណ៍តបថា: នាងខ្ញុំសុំរក្សាតាមសេចក្ដីថ្លែងការណ៍ និងការទាមទាររបស់មេធាវីសហភាតាលោក [redacted] និងលោក [redacted] ទុកជាបានការដដែលទាំងស្រុង។

-ឈ្មោះ [redacted] ចិត្រ្តា តំណាងឱ្យដើមចោទធនាគារប្រៃសណីយ៍សាខាខេត្តកំពង់ស្ពឺ ធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្ញុំបាទសុំរក្សាដូចសេចក្ដីថ្លែងការណ៍ និងការទាមទាររបស់ខ្ញុំបាទខាងលើទុកនៅដដែល។

-សហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងប្រពន្ធឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) អវត្តមាន។

## ចំណុចវិវាទ និងចំណុចគ្មានវិវាទ

### -ចំណុចមានវិវាទ

១-សហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) សុំប្រានចោលការប្រាក់ចំនួន ២២.០៤៨,៧៦ (ពីរម៉ឺនពីរពាន់សូន្យរយសែសិបប្រាំបីក្បៀសចិតសិបប្រាំមួយសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ចំណែកសហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) សុំដកឈ្មោះរបស់ខ្លួនចេញពីអ្នកធានា ភាគីសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) បានយល់ព្រម និងឯកភាពឱ្យដកឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ពីការទទួលខុសត្រូវលើការសងប្រាក់ពីធនាគារ ដោយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ទទួលខុសត្រូវក្នុងការសងប្រាក់ទៅធនាគារ តែភាគីដើមចោទមិនឯកភាពក្នុងការដកឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ពីអ្នកធានានោះទេ។

២-សហចុងចម្លើយឈ្មោះ [redacted] សម្អស្ស [redacted] សម្អស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) សុំប្រានចោលប្រាក់ពិន័យចំនួន ៥០.៦៥២,៩៥ (ប្រាំម៉ឺនសូន្យពាន់ប្រាំមួយរយហាសិបពីរក្បៀសកៅសិបប្រាំសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ ចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

៣-សហចុងចម្លើយឈ្មោះ [redacted] សម្អស្ស [redacted] សម្អស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) សុំប្រានចោលបង់អត្រាការប្រាក់ចំនួន ១,២% ក្នុងមួយខែ និងប្រាក់ពិន័យចំនួន ២៤% ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ខកខានមិនបានសង ដែលសមាមាត្រទៅនឹងថ្ងៃខកខានសងមកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៤-សហចុងចម្លើយឈ្មោះ [redacted] សម្អស្ស [redacted] សម្អស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) សុំប្រានចោលសងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក។

**-ចំណុចគ្មានវិវាទ:**

សហចុងចម្លើយឈ្មោះ [redacted] សម្អស្ស [redacted] សម្អស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ទទួលស្គាល់ប្រាក់ដើមចំនួន ៤២.៥០០,០៣ (បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក។

<u>ភស្តុតាងដែលភាគីដើមចោទដាក់ជូនតុលាការពិនិត្យរួមមាន៖</u>

១.កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។
២.តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។
៣.កិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។
៤.កិច្ចសន្យាធានា ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។
៥.អត្តសញ្ញាណប័ណ្ណ។
៦.លិខិតប្រគល់សិទ្ធិលេខ ធបក ០០៥៧-០២-២១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១។
៧.លិខិតក្រើនរំលឹក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧។
៨.លិខិតស្នើសុំទប់ស្កាត់ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩។
៩.លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩។
១០.កំណត់ហេតុប្រគល់ទទួលឯកសារ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩។
១១.Account Statment ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១។
១២.វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម។
១៣.កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន។
១៤.លិខិតស្តីពីការរំលាយកិច្ចសន្យាការងារ។
១៥.តារាងសង្ខេបចំនួនទឹកប្រាក់ដែលនៅជំពាក់របស់អតិថិជនឈ្មោះ [redacted] លក្ខិណា។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១-ពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ របស់ដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ តំណាងដោយឈ្មោះ [redacted] ចិត្រ្តា ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ តួនាទីនាយក



Scanned with CamScanner

សាខា [redacted] សាខាខេត្តកំពង់ស្ពឺ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចឱ្យតុលាការលើកយកធ្វើការទាញហេតុផលតាមបញ្ញត្តិមាត្រា ៩, មាត្រា ២៣ និងចេញសាលក្រមតាមបទបញ្ញត្តិមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ដើមចោទធនាគារ [redacted] សាខាខេត្តកំពង់ស្ពឺ តំណាងដោយឈ្មោះ [redacted] ចិត្រ្តា បានទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ៤២.៥០០,០៣ (**បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន**) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦, តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦, កិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងតារាងសង្ខេបចំនួនទឹកប្រាក់ដែលនៅជំពាក់របស់អតិថិជនឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) រវាង [redacted] សាខាខេត្តកំពង់ស្ពឺ ជាមួយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ឃើញថា កិច្ចសន្យានេះ សហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) បានទទួលស្គាល់ថា ខ្លួនពិតជានៅជំពាក់ប្រាក់ដើមចោទចំនួន ៤២.៥០០,០៣ (**បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន**) ដុល្លារអាមេរិក ប្រាកដមែន ដែលកិច្ចសន្យានេះ ធ្វើឡើងដោយមានការព្រមព្រៀង គ្មានវិការៈ ស្របតាមមាត្រា ៣៨៥ (**ការបង្ហាញឆន្ទៈដែលគ្មានវិការៈ**) នៃក្រមរដ្ឋប្បវេណី។ ការលើកឡើងនេះអាចឱ្យតុលាការជឿបាន ដោយហេតុថា ដើមចោទមានភស្តុតាងជាឯកសារច្បាស់លាស់ អាចឱ្យតុលាការលើកយកមកពិចារណា និងសម្រេចបាន។

៣-ការប្រគល់ ឬទទួលប្រាក់នេះ គឺជាការប្រគល់ក្រោមទម្រង់ជាកិច្ចសន្យាខ្ចីបរិភោគ ដោយអនុលោមតាមមាត្រា ៥៧៨ (**និយមន័យនៃការខ្ចីបរិភោគ**) និងមាត្រា ៥៨៣ (**សិទ្ធិលើបំណុលដែលជាការប្រាក់**) នៃក្រមរដ្ឋប្បវេណី បើយើងពិនិត្យមើលឃើញថា សហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកាលវិភាគសងប្រាក់របស់ [redacted] សាខាខេត្តកំពង់ស្ពឺ ដែលបានកំណត់ក្នុងកិច្ចសន្យានោះឡើយ។

៤-ឈ្មោះ [redacted] ចិត្រ្តា ជាតំណាងឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ បានទាមទារឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ២២.០៤៨,៧៦ (**ពីរម៉ឺនពីរពាន់សូន្យរយសែសិបប្រាំបីក្បៀសចិតសិបប្រាំមួយសេន**) ដុល្លារអាមេរិក មកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។ តាមការទាមទារការប្រាក់ខាងលើ ដើមចោទមិនបានផ្តល់ភស្តុតាងនៃការគណនាចំនួនការប្រាក់មកតុលាការឡើយ ប៉ុន្តែយោងតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ដើមចោទ និងសហចុងចម្លើយពិតជាបានកំណត់អំពីការប្រាក់ដែលត្រូវបង់តាមអត្រា ១,២០% (**មួយក្បៀសម្ភៃភាគរយ**) ក្នុងមួយខែ ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវតាមប្រកាសរបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ លេខ: ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ត្រង់ប្រការ ១ ដែលបានកំណត់ជាក់លាក់អំពីការកំណត់អត្រាការប្រាក់ថា: អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ១៧ (**អត្រាការប្រាក់ដែលត្រូវកម្រិត ជាអាទិ៍**) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឱ្យលើសពី ១៨% (**ដប់ប្រាំបីភាគរយ**) ក្នុងមួយឆ្នាំ។ យោងតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ឃើញថា កាលបរិច្ឆេទចុងក្រោយនៃកាតព្វកិច្ចរបស់សហចុងចម្លើយ គឺថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ ដែលកាលបរិច្ឆេទនេះបានកន្លងហួស ហេតុដូច្នេះគប្បីតុលាការសម្រេចអំពីអត្រាការប្រាក់តាម

ការព្រមព្រៀងរបស់ភាគីឱ្យស្របតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។

៥-ឈ្មោះ [redacted] ចិត្រ្តា តំណាងឱ្យដើមចោទ [redacted] ក.អ សាខាខេត្តកំពង់ស្ពឺ បានទាមទារឱ្យសហចុងចម្លើយបង់អត្រាការប្រាក់ ១,២០% (មួយក្បៀសម្ភៃភាគរយ) ក្នុងមួយខែ លើចំនួនទឹកប្រាក់ដែលត្រូវបង់ឱ្យ [redacted] សាខាខេត្តកំពង់ស្ពឺ គិតចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។ តាមសំអាងហេតុខាងលើបានសម្រេចអំពីអត្រាការប្រាក់តាមការព្រមព្រៀងរបស់ភាគីឱ្យស្របតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ឃើញថា កាលបរិច្ឆេទចុងក្រោយនៃកាតព្វកិច្ចរបស់សហចុងចម្លើយ គឺថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ មិនមែនថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ដូចការទាមទាររបស់អ្នកតំណាងឱ្យដើមចោទឡើយ។ ក្នុងករណីនេះឃើញថា សហចុងចម្លើយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ នោះទេ ហើយក្នុងករណីហួសកាលបរិច្ឆេទចុងក្រោយនៃកាតព្វកិច្ចរបស់សហចុងចម្លើយ ដើមចោទ និងសហចុងម្លើយក៏មិនបានកំណត់អំពីអត្រាការប្រាក់ឡើយ យោងតាមមាត្រា ៣១៨ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់) នៃក្រមរដ្ឋប្បវេណី បានចែងថាៈ ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ ចំនួន ៥% (ប្រាំភាគរយ) ក្នុងមួយឆ្នាំ ហេតុដូច្នេះគប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

៦-ឈ្មោះ [redacted] ចិត្រ្តា តំណាងឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ បានទាមទារឱ្យសហចុងចម្លើយសងប្រាក់ពិន័យចំនួន ៥០.៦៥២,៩៥ (ប្រាំម៉ឺនសូន្យពាន់ប្រាំមួយរយហាសិបពីរក្បៀសកៅសិបប្រាំសេន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។ តាមការទាមទារប្រាក់ពិន័យខាងលើ ដើមចោទមិនបានផ្តល់ភស្តុតាងនៃការគណនាចំនួនការប្រាក់មកតុលាការឡើយ ប៉ុន្តែយោងតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ត្រង់ប្រការ ២ ចំណុច ២.២ ដើមចោទ និងសហចុងចម្លើយពិតជាបានកំណត់អំពីប្រាក់ពិន័យដែលមានអត្រា ២៨% (ម្ភៃប្រាំបួនភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលខកខានមិនបានសង ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លេខៈ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ត្រង់ប្រការ ២ ដែលបានកំណត់ជាក់លាក់អំពីការកំណត់អត្រាការប្រាក់ថាៈ អត្រាការប្រាក់ដែលព្រមព្រៀងជាមុនក្នុងការសងសំណង ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឱ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។ ដោយអនុលោមតាមប្រការ ២ ខាងលើ តុលាការឃើញថា អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ គឺត្រូវកំណត់មិនឱ្យលើសពី ២៧% (ម្ភៃប្រាំពីរភាគរយ) ក្នុងមួយឆ្នាំឡើយ (១៨%x១,៥=២៧%) ឬស្មើនឹង ២,២៥% (ពីរក្បៀសម្ភៃប្រាំភាគរយ) ក្នុងមួយខែ។ ដោយពិនិត្យទៅលើការទាមទារអត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលមានកម្មវត្ថុជាប្រាក់របស់ដើមចោទ ចំពោះសហចុងចម្លើយ ឃើញថាត្រឹមត្រូវនឹងគោលការណ៍ខាងលើ ដូច្នេះតុលាការគប្បីសម្រេចអំពីអត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមាន



Scanned with CamScanner

កម្មវត្ថុជាប្រាក់ តាមការព្រមព្រៀងរបស់ភាគី ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។

៧-ឈ្មោះ [redacted] ចិន្ត្រា តំណាងឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ បានទាមទារឱ្យសហចុងចម្លើយបង់ប្រាក់ពិន័យចំនួន ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ខកខានមិនបានសង ដែលសមាមាត្រទៅនឹងថ្ងៃខកខានសងមកឱ្យដើមចោទ គិតចាប់ពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន។ តាមសំអាងហេតុខាងលើបានសម្រេចអំពីអត្រាការប្រាក់ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ តាមការព្រមព្រៀងរបស់ភាគី ដែលមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ រួចហើយ ហេតុដូច្នេះគប្បីតុលាការមិនធ្វើការសម្រេចទៀតឡើយ។

៨-ឈ្មោះ [redacted] ចិន្ត្រា តំណាងឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ បានទាមទារឱ្យសហចុងចម្លើយសងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់ ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក ប៉ុន្តែដោយហេតុថា ដើមចោទមិនបានបង្ហាញភស្តុតាងទាក់ទងទៅនឹងចំណាយនោះទេ ដូច្នេះតុលាការនឹងធ្វើការសម្រេចតាមតថភាពជាក់ស្តែង ដោយអនុលោមតាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី។

៩-ឈ្មោះ [redacted] ចិន្ត្រា តំណាងឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ ស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម, ការប្រាក់, ប្រាក់ពិន័យ និងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់ តុលាការយល់ឃើញថា មានភាពចាំបាច់នៅក្នុងការអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម យោងតាមមាត្រា ១៩៦ (ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នេះតុលាការគប្បីប្រកាសថា សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្ន បានលើប្រាក់ដើម។ ចំពោះការប្រាក់, ប្រាក់ពិន័យ និងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់ តុលាការយល់ឃើញថា ពុំមានភាពចាំបាច់នៅក្នុងការអនុវត្តជាបណ្តោះអាសន្នឡើយ ហេតុដូច្នេះតុលាការគប្បីច្រានចោលការស្នើសុំអនុវត្តជាបណ្តោះអាសន្នលើការប្រាក់, ប្រាក់ពិន័យ និងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់របស់ដើមចោទ។

១០-ឈ្មោះ [redacted] ចិន្ត្រា តំណាងឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ ស្នើសុំតុលាការសម្រេចប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ។ ចំពោះប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមមាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី"។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

១១-យោងតាមភស្តុតាងជាឯកសារដែលដើមចោទបានដាក់ជូនតុលាការពិនិត្យ មានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦, តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ និងតារាងសង្ខេបចំនួនទឹកប្រាក់ដែលនៅជំពាក់របស់អតិថិជនឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) រវាង [redacted] សាខាខេត្តកំពង់ស្ពឺ និងឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) តាមការអះអាងរបស់សហចុងចម្លើយឈ្មោះ ភ័ត់ សម្ផស្ស (ភ័ត សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ដែលមានលោក [redacted] សាមៀន និងលោក [redacted] តុលា ជាអ្នក

តំណាងដោយអាណត្តិ បានបញ្ជាក់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: ខ្លួនពិតជាបានខ្ចីលុយពីធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាខេត្តកំពង់ស្ពឺ ប្រាកដមែន យោងតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ឃើញថា ពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយនឹងធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាខេត្តកំពង់ស្ពឺ ប្រាកដមែន តាមមាត្រា ៩២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា ក្នុងករណីដែលបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គីភាព ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ឬឱ្យកូនបំណុលទាំងអស់ អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ដោយព្រមគ្នា ឬដោយបន្តបន្ទាប់ ដូច្នេះតុលាការគប្បីសម្រេចឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស ([redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ទទួលបន្ទុកនូវកាតព្វកិច្ចដោយសាមគ្គីភាពនេះ។

១២-តាមមាត្រា ៩០០ (ការបង្កើតកិច្ចសន្យាធានា) កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ចែងថា "កិច្ចសន្យាធានាត្រូវបង្កើតឡើង ដោយសារបុគ្គលដែលមានបំណងធ្វើជាអ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថា ខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ឬទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីកូនបំណុលមានកាតព្វកិច្ចចម្បងនោះពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយម្ចាស់បំណុលបានយល់ព្រមអំពីការសន្យានោះ។" តាមមាត្រា ៩០៣ (ទំហំនៃកាតព្វកិច្ចធានា) កថាខណ្ឌទី១ ចែងថា "កាតព្វកិច្ចធានាត្រូវរាប់បញ្ចូល ទាំងការប្រាក់ ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា និងសំណងការខូចខាត ដែលទាក់ទងនឹងកាតព្វកិច្ចចម្បង និងអ្វីដែលកើតឡើងបន្ទាប់បន្សំ ពីកាតព្វកិច្ចចម្បងនោះ។" និងតាមកិច្ចសន្យាធានា ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] សាមិត ភេទប្រុស និងឈ្មោះ [redacted] សារ៉ាន់ ភេទស្រី ត្រង់ប្រការ ១ មានសេចក្តីថា "ពួកខ្លួនសូមអះអាងលើបំណុលនេះទាំងស្រុង ប្រសិនបើភាគី (ខ) មិនបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យាខ្ចីប្រាក់ដោយប្រការណាមួយនោះ ពួកខ្លួនសូមធានាទទួលខុសត្រូវ និងបង់ប្រាក់បំណុលសងជំនួសទាំងស្រុងដោយគ្មានលក្ខខណ្ឌ" និងប្រការ ៣ មានសេចក្តីថា "បើពុំប្រាកដ ដូចកិច្ចសន្យាធានាដោយប្រការណាមួយ ពួកខ្លួនសុខចិត្តលក់ទ្រព្យសម្បត្តិអះអាងធានាខាងលើ ឬឱ្យភាគី (ក) ប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬទៅតុលាការ ដើម្បីរឹបអូសទ្រព្យសម្បត្តិដាក់ធានាបំណុលនេះ លក់ឡាយឡុង ដើម្បីយកប្រាក់មកទូទាត់បំណុលជំនួសភាគី (ខ) ដែលនៅជំពាក់ភាគី (ក) ឱ្យបានគ្រប់ចំនួន រួមទាំងប្រាក់ដើម ទាំងការប្រាក់ និងប្រាក់ពិន័យផង។ ក្នុងករណីមិនទាន់សងគ្រប់ ត្រូវបន្តកាតព្វកិច្ចសងបំណុលដែលនៅសល់បន្ថែមទៀត រហូតទាល់តែគ្រប់ចំនួន។" ឃើញថា សហចុងចម្លើយឈ្មោះ [redacted] សាមិត ភេទប្រុស និងឈ្មោះ [redacted] សារ៉ាន់ ភេទស្រី បានយល់ព្រមទទួលនូវកាតព្វកិច្ចជំនួសសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស (ភ៉ត សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ត្រឹមកម្រិតនៃប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ។ ហេតុដូច្នេះ សហចុងចម្លើយឈ្មោះ [redacted] សាមិត ភេទប្រុស និងឈ្មោះ [redacted] សារ៉ាន់ ភេទស្រី ត្រូវទទួលបន្ទុកនូវកាតព្វកិច្ចដោយសាមគ្គីភាពនេះជាមួយសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) ស្របតាមមាត្រា ៩២១ (អត្ថន័យនៃកាតព្វកិច្ចដោយសាមគ្គីភាព) និងមាត្រា ៩២២ (ការបង្កើតកិច្ចសន្យាដោយសាមគ្គីភាព) នៃក្រមរដ្ឋប្បវេណី។

១៣-សហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា ([redacted] លក្ខិណា) បានអះអាងថា ខ្លួនពិតជាបានខ្ចីប្រាក់ពីដើមចោទ និងមានឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) ជាអ្នកធានា ប្រាកដមែន យោងតាមកិច្ចសន្យាធានា ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ

២០១៦ ដោយខ្លួនស្នើសុំឱ្យតុលាការដកឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) ចេញពីអ្នកធានា គឺខ្លួនជាអ្នកទទួលខុសត្រូវខ្លួនឯង ចំណែកសហចុងចម្លើយឈ្មោះ [redacted] សាមិត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) ដែលមានមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិបានស្នើសុំឱ្យតុលាការ ច្រានចោលការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ របស់ដើមចោទទាំងស្រុង និងសុំឱ្យដកឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) ចេញពីអ្នកធានា និងស្នើសុំឱ្យតុលាការបង្គាប់ឱ្យដើមចោទប្រគល់ប្លង់ដីដែលបានដាក់ធានាមកឱ្យសហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) វិញ ឃើញថា ការស្នើសុំរបស់សហចុងចម្លើយ គឺពុំបានដាក់ពាក្យបណ្តឹងតប ដើម្បីឱ្យតុលាការពិនិត្យក្នុងការសម្រេចតាមមាត្រា ៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះទេ។ ហេតុនេះ គប្បីតុលាការមិនធ្វើការពិចារណាទៅលើការស្នើសុំរបស់សហចុងចម្លើយឡើយ។

១៤-សហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) ពិតជាបានបង្កើតកិច្ចសន្យាធានា ឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស) និងឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) ជាមួយនឹងដើមចោទ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាខេត្តកំពង់ស្ពឺ ប្រាកដមែន យោងតាមកិច្ចសន្យាធានា ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ សហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) បានធានា រួមទាំងប្រាក់ដើម ទាំងការប្រាក់ និងប្រាក់ពិន័យផង យោងតាមមាត្រា ៩០០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា "កិច្ចសន្យាធានាត្រូវបង្កើតឡើង ដោយសារបុគ្គលដែលមានបំណងធ្វើជាអ្នកធានា បានសន្យាជាមួយនឹងម្ចាស់បំណុលថា ខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ឬទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចចម្បងនោះពុំអនុវត្តកាតព្វកិច្ចចម្បងរបស់ខ្លួន ហើយម្ចាស់បំណុលបានយល់ព្រមអំពីការសន្យានោះ។ ដូច្នេះតុលាការគប្បីសម្រេចឱ្យសហចុងចម្លើយឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) ទទួលបន្ទុកនូវកាតព្វកិច្ចជាអ្នកធានានេះ។

## សេចក្តីសម្រេចបញ្ចប់

I-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស), ឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា), ឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) សងប្រាក់ដើមចំនួន ៨២.៥០០,០៣ (ប៉ែតសិបពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ [redacted] ក.អ សាខាខេត្តកំពង់ស្ពឺ ដែលមានឈ្មោះ [redacted] ចិត្រ្តា ជាអ្នកតំណាង។

II-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស), ឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា), ឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) សងការប្រាក់ក្នុងអត្រា ១,២០ (មួយក្បៀសម្ភៃភាគរយ) ក្នុងមួយខែ នៃប្រាក់ដើមចំនួន ៨២.៥០០,០៣ (ប៉ែតសិបពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក មកឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ ដែលមានឈ្មោះ [redacted] ចិត្រ្តា ជាអ្នកតំណាង គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១។

III-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស), ឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា), ឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ ([redacted] សារ៉ាន់) បង់ការប្រាក់ក្នុងអត្រា ៥% (ប្រាំភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលត្រូវបង់ឱ្យដើមចោទ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខា



Scanned with CamScanner

ខេត្តកំពង់ស្ពឺ ដែលមានឈ្មោះ [redacted] ចិត្រា ជាអ្នកតំណាង គិតចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

IV-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស), ឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា), ឈ្មោះ [redacted] សាមិត និងឈ្មោះ [redacted] សារ៉ាន់ [redacted] សារ៉ាន់) សងការប្រាក់ពិន័យក្នុងអត្រា ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើចំនួនទឹកប្រាក់ដែលត្រូវបង់ឱ្យដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ ដែលមានឈ្មោះ [redacted] ចិត្រា ជាអ្នកតំណាង គិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន។

V-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សម្ផស្ស [redacted] សម្ផស្ស), ឈ្មោះ [redacted] លក្ខិណា [redacted] លក្ខិណា) បង់សងការខាតបង់ពេលវេលា សោហ៊ុយចំណាយ និងសេវាផ្នែកច្បាប់ ចំនួន ៤.០០០.០០០ (បួនលាន) រៀល ឱ្យទៅដើមចោទ [redacted] សាខាខេត្តកំពង់ស្ពឺ ដែលមានឈ្មោះ [redacted] ចិត្រា ជាអ្នកតំណាង។ ការទាមទារលើសពីនេះច្រានចោល។

VI-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើមចំនួន ៤២.៥០០,០៣ (បួនម៉ឺនពីរពាន់ប្រាំរយក្បៀសសូន្យបីសេន) ដុល្លារអាមេរិក។

VII-ច្រានចោល ការទាមទារអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុច II, III, IV និង V នៃសេចក្តីសម្រេចបញ្ចប់នេះ។

VIII-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស .២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ២០ នាទី ព្រឹក នៅសាលសវនាការ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner